# របាយការណ៍ប្រចាំឆ្នាំ
# ៣១ ធ្នូ ២០២៤

## អរ អិម អេ (ខេមបូឌា) ម.ក

## R M A (CAMBODIA) PLC.



អ អិម អេ (ខេមបូឌា)

ផ្ទះលេខ ២៧ ផ្លូវ១៣៤ ប្រអប់សំបុត្រ ៥៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ
(៨៥៥) ២៣ ៨៨៨ ០០០ ទូរសារ (៨៥៥) ២៣ ៤២៦ ៧៥២

www.cambodia.rmagroup.net

## ចក្ខុវិស័យ

ទស្សនៈវិស័យរបស់យើងគឺដើម្បីក្លាយទៅជាដៃគូដែលទុកចិត្តបំផុត និងយូរអង្វែងសម្រាប់ការអភិវឌ្ឍន៍ និងវិបុលភាពនៅកម្ពុជា៖

| ធនធានមនុស្ស | អតិថិជន | អ្នកផ្គត់ផ្គង់ |
|---|---|---|
| ជាមនុស្សដែលមានការលើកទឹកចិត្តខ្ពស់ និងមានការចូលរួម និងមានភាពងប់ងល់ការទទួលខុសត្រូវ ភាពច្នៃប្រឌិត និងភាពច្នៃប្រឌិតក្នុងការស្វែងរកដំណោះស្រាយល្អបំផុតចំពោះបញ្ហារបស់មនុស្សដើម្បីធ្វើអោយជីវិតប្រសើរឡើង។ | អតិថិជនមានភាពសប្បាយរីករាយដែលត្រូវបានបំរើសេវាកម្មដោយបុគ្គលដែលទទួលបានការកោតសរសើរពីក្រុមហ៊ុន RMAC ជាមួយនឹងអ្នកជំនាញ គុណភាពផលិតផល ដំណោះស្រាយ និងសេវាកម្មអតិថិជនដែលគ្មានគូរប្រៀប។ | បណ្តាញអ្នកផ្គត់ផ្គង់អតិថិជនដែលឈ្នះដោយការគោរពគ្នា និងមានមហិច្ឆិតាចែករំលែកដើម្បីធ្វើឱ្យជីវិតកាន់តែប្រសើរឡើង។ |

## បេសកកម្ម និងតម្លៃ

អ អិម អេ (ខេមបូឌា) ម.ក (“RMAC” ឬ “**ក្រុមហ៊ុន**”) ជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យផ្គត់ផ្គង់គ្រឿងយន្តនៅក្នុងប្រទេសកម្ពុជា។

RMAC បានចូលមកក្នុងទីផ្សារប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ ក្នុងនាមជាផ្តល់ដំណោះស្រាយខាងផ្នែកពាណិជ្ជកម្ម និងក្រៅពាណិជ្ជកម្ម ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងដឹកជញ្ជូន។

ក្រុមហ៊ុនបានរីកចំរើនយ៉ាងឆាប់រហ័សទន្ទឹមគ្នានិងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ហើយបានពង្រីកខ្លួនក្នុងវិស័យ យានយន្ត កសិកម្ម សំណង់ ឧបករណ៍លើកដាក់ ឧបករណ៍សម្អាត និង សេវាកម្មបន្ទាប់ពីផ្នែកលក់។

RMAC បានទទួលកេរ្តិ៍ឈ្មោះក្នុងនាមជាអ្នកចែកចាយយានយន្តនិងគ្រឿងចក្រលំដាប់ពិភពលោក ដោយរួមបញ្ចូលម៉ាក Ford (តាំងពីឆ្នាំ ១៩៩៧), TCM (តាំងពីឆ្នាំ២០០៨), JCB (តាំងពីឆ្នាំ២០១០), FUSO (តាំងពីឆ្នាំ២០១០), John Deere (តាំងពីឆ្នាំ២០១១), Jaguar Land Rover (តាំងពីឆ្នាំ២០១៣), MS Pallet (តាំងពីឆ្នាំ២០១៣), Megger & Sebar (តាំងពីឆ្នាំ ២០១៣), GenieGrips (តាំងពីឆ្នាំ២០១៧), Hako (តាំងពីឆ្នាំ២០១៨), PowerBoss (តាំងពីឆ្នាំ២០១៨) , AJAX (តាំងពីឆ្នាំ ២០១៩), Piaggio (តាំងពីឆ្នាំ២០២០), Changan (តាំងពីឆ្នាំ២០២២), Haulotte (តាំងពីឆ្នាំ២០២២), សេវាកម្មក្រោយការលក់ Mercedes-Benz (តាំងពីឆ្នាំ២០២៣), គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ) (តាំងពីឆ្នាំ២០២៣), Jeep និង RAM មកពីគ្រុប Stellantis (ឆ្នាំ២០២៤).

សម្រាប់អតិថិជនរបស់យើងនៅក្នុងទីផ្សារ RMAC គឺជាដៃគូរយូរអង្វែងជាជាងអ្នកផ្គត់ផ្គង់យូរអង្វែង។ យើងបានវិនិយោគក្នុងការផ្តល់ការងារ និងការគាំទ្រទៅលើគុណភាពនៃផលិតផលរបស់យើងជាមួយនឹងការប្តេជ្ញាចិត្តមិនផ្លាស់ប្តូរដើម្បីផ្តល់សេវាកម្មបន្ទាប់ពីការលក់ជានិរន្តរ៍។



ភាពច្នៃប្រឌិត

RMAC ទទួលបានភាពជោគជ័យ ទៅលើការផ្តល់ដំណោះស្រាយច្នៃប្រឌិតដែលត្រូវតាមតម្រូវការរបស់អតិថិជនយ៉ាងជាក់លាក់។



ភាពសុចរិត

RMAC តែងតែខិតខំប្រឹងប្រែងយ៉ាងល្អបំផុតសម្រាប់អតិថិនរបស់ខ្លួន។ អ្វីក៏ដោយដែលក្រុមហ៊ុនបានធ្វើគឺធ្វើដោយភាពត្រឹមត្រូវនិងយកចិត្តទុកដាក់។



ភាពអត់ធ្មត់

RMAC នៅតែបន្តការវិនិយោគដ៏យូរអង្វែងនៅក្នុងអាជីវកម្មរបស់ខ្លួន ភាពជាដៃគូជាមួយអតិថិជន និងភាពស្ថិតស្ថេរនៃផលិតផល និងដំណោះស្រាយផងដែរ។

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ២០២៤ | ២០២៣ | ២០២២ |
| --- | --- | --- | --- |
| ទ្រព្យសកម្មសរុប | ៨៧៩.៥៤១.៦៥៦ | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ |
| បំណុលសរុប | ៣៥៩.៧៦៣.០០១ | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ |
| មូលធនក្រុមហ៊ុនសរុប | ៥១៩.៧៧៨.៦៥៥ | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ |
| ប្រាក់ចំណេញ(ខាត) / (គិតជាពាន់រៀល) | ២០២៤ | ២០២៣ | ២០២២ |
| ចំណូលសរុប | ១.៦៣១.០៩៥.៦៩៤ | ១.៨០០.៣៦២.០៩៤ | ២.២០៣.២៥៣.៤៥៣ |
| ប្រាក់ចំណេញមុនបង់ពន្ធ(ខាត)/ | ៨៨.០៨៣.៣៣៩ | ១៣៩.៤២០.៣០០ | ២៩៦.០៥៨.៩១៣ |
| ប្រាក់ចំណេញ(ខាត)/ក្រោយបង់ពន្ធ | ៦៧.៦១៩.០៩០ | ១១៣.៧២៣.១៣៣ | ២៤៣.៥៦៥.៥៣០ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៥៩.៩៨៥.២២៧ | ១០៩.៨៧៦.៣៦៦ | ២៤៧.៦៦៨.៨២៣ |
| អនុបាតហិរញ្ញវត្ថុ | ២០២៤ | ២០២៣ | ២០២២ |
| អនុបាតសាធនភាព | ០,៧ | ១,២ | ១,០ |
| អនុបាតចរន្ត (Current Ratio) | ៤,២ | ២,៥ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ១,៨ | ០,៦ | ០,៧ |
| អនុបាតផលចំណេញ | ២០២៤ | ២០២៣ | ២០២២ |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ៦,១% | ១១,១% | ៣៣,១% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ១១,៧% | ២៣,៣% | ៦៨,៤% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៥,០% | ១៧,៤% | ១៩,០% |
| គម្លាតចំណេញ (Profit Margin) | ៣,៧% | ៦,១% | ១១,២% |
| អនុបាតលទ្ធភាពសងការប្រាក់ | ៤,៥ | ៥,៧ | ២៤,១ |

# ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប









## ប្រាក់ចំណូល និងចំណូលសុទ្ធ ( គិតជាពាន់រៀល )



# សមាជិកក្រុមប្រឹក្សាភិបាល



Wiedmann Christian | ងន សាំង | Kevin Whitcraft | Tom Whitcraft | Vichit Ith

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

លោក ងន សាំង
អភិបាលប្រតិបត្តិ

លោក Tom Whitcraft
អភិបាលមិនប្រតិបត្តិ

លោក Wiedmann Christian
អភិបាលមិនប្រតិបត្តិ

លោក Ith Vichit
អភិបាលឯករាជ្យ

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ **ក្រុមហ៊ុន អ អិម អេ (ខេបូឌា) ម.ក (តទៅហៅកាត់ថា "RMAC")** ស្របតាមតម្រូវការរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ឧស្សាហកម្មរថយន្តកម្ពុជាមានការកើនឡើងតិចតួចក្នុងឆ្នាំ២០២៤ ដោយការលក់សរុបមានចំនួន +៤% ធៀបនឹងឆ្នាំមុន ជាមួយនឹងកំណើនទីផ្សារលក់រថយន្តថ្មី កើនឡើងចំនួន +១៣%។ តាមការប៉ាន់ស្មាន ទីផ្សាររថយន្តថ្មីមានប្រហែល ៥១% នៃទីផ្សាររថយន្តសរុបនៅកម្ពុជា ដែលធ្វើឱ្យការលក់រថយន្តថ្មីមានចំនួនលើសការលក់រថយន្តមួយទឹក។

ក្រុមហ៊ុន RMAC បានបន្តរក្សាភាពឈានមុខគេក្នុងវិស័យយានយន្តនៅប្រទេសកម្ពុជា នៅក្នុងទីផ្សាររថយន្តធម្មតា ជាមួយរថយន្តម៉ាក Ford និងម៉ាក Changan ទីផ្សាររថយន្តប្រណិតជាមួយនឹងម៉ូដែល Land Rover មិនត្រឹមតែប៉ុណ្ណោះក្នុងនាមជាអ្នកចូលរួមចំណែកដ៏សំខាន់នៅក្នុងវិស័យឧស្សាហកម្ម តាមរយៈការនាំចូល និងចែកចាយផលិតផលត្រាក់ទ័រម៉ាក Jonh Deere ទន្ទឹមនឹងនេះមានការរីកចម្រើនជាមួយនឹងការលក់រថយន្តដឹកទំនិញម៉ូដែល Mitsubishi Fuso គ្រឿងចក្រធុនធ្ងន់ម៉ូដែល JCB និងឧបករណ៍លើកដាក់សម្ភារៈម៉ូដែល TCM។

ក្រុមហ៊ុន RMAC បានបន្តបើកសម្ពោធរថយន្តស៊េរីថ្មីៗ (Deepal មកពី Changan Group និង Jeep & RAM មកពី Stellantis Group) និងពង្រឹងសកម្មភាពរបស់ខ្លួនជាមួយនឹងផលិតផលសំខាន់ៗដូចខាងក្រោម៖

- រថយន្ត Ford Territory Dark Edition
- រថយន្ត Deepal L07
- រថយន្ត Deepal S07
- រថយន្ត Range Rover SV PHEV
- រថយន្ត Mitsubishi Fuso 1.5T FE71
- រថយន្ត All-New Jeep Wrangler Rubicon

ក្រុមហ៊ុន RMAC បានបន្តតួនាទីរបស់ខ្លួនជាអ្នកឧបត្ថម្ភចម្បងដល់ក្រុមហ៊ុន RMA Automotive Cambodia (RMAAC) ដោយរថយន្ត FORD រាប់ពាន់គ្រឿង (Ford Ranger Wildtrak និង Ford Everest)

ត្រូវបានផលិត និងលក់ដោយ ក្រុមហ៊ុន RMAC ចាប់តាំងពីការបើកដំណើរការរោងចក្រនៅឆ្នាំ ២០២២។

ខ្ញុំមានមោទនភាពយ៉ាងខ្លាំងក្នុងការចែករំលែកថា ម៉ូដែលដែលផលិតដោយក្រុមហ៊ុន RMAAC តាំងពីខែកញ្ញា ឆ្នាំ២០២៤ គឺជារថយន្តដំបូងគេក្នុងប្រទេសកម្ពុជាដែលទទួលបាន លេខVIN (លេខសម្គាល់អត្តសញ្ញាណយានយន្ត) ទទួលស្គាល់ប្រភពដើមនៃយានយន្តដែលផលិតនៅក្នុងប្រទេសកម្ពុជា។

ជាផ្នែកនៃយុទ្ធសាស្ត្ររបស់ខ្លួន ក្រុមហ៊ុន RMAC បានពង្រីកបណ្តាញរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាជាមួយនឹងមជ្ឈមណ្ឌលត្រួតពិនិត្យមុនការដឹកជញ្ជូនរថយន្ត និងមជ្ឈមណ្ឌលដឹកជញ្ជូនរថយន្ត Ford នៅតំបន់បឹងបៃតង។ ផ្នែកគ្រឿងចក្រកសិកម្ម និងបរិក្ខារធុនធ្ងន់ បានរៀបចំពិធីសម្ពោធអគារថ្មីរបស់ខ្លួន នៅលើផ្លូវជាតិលេខ៦ គឺអគារតាំងបង្ហាញ John Deere 3S ថ្មីនៅខេត្តត្បូងឃ្មុំដែលបានសម្ពោធឱ្យប្រើប្រាស់នៅចុងឆ្នាំនេះ។

ក្រុមហ៊ុន RMAC ក៏ផ្តល់នូវភាពជឿជាក់ និងភាពងាយស្រួលលំដាប់ពិភពលោកនូវសេវាកម្មក្រោយការលក់ ជាមួយនឹងមជ្ឈមណ្ឌលថែទាំរថយន្តដែលត្រូវគ្រប់គ្រងយ៉ាងពេញលេញមាននូវផ្នែកបច្ចេកទេសសំខាន់ៗទាំងអស់របស់យើង។ យើងកំពុងបន្តធ្វើឱ្យប្រសើរឡើងនូវបរិក្ខាររបស់យើង ដើម្បីបំពេញតម្រូវការរបស់អតិថិជនបន្ថែមទៀត។

ក្រុមហ៊ុនរបស់យើង និងអ្នកគ្រប់គ្រងរបស់យើងបានពង្រឹងទំនាក់ទំនងដ៏រឹងមាំជាមួយវិទ្យាស្ថាន Bendigo Kangan (BKI) នៃប្រទេសអូស្ត្រាលី ជាមួយនឹងភាពជាដៃគូដ៏ខ្ពង់ខ្ពស់ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតមជ្ឈមណ្ឌលឧត្តមភាពរថយន្តដំបូងគេនៅកម្ពុជា (ACEC)។ គោលបំណងគឺដើម្បីបណ្តុះបណ្តាល និងទាក់ទាញអ្នកមានទេពកោសល្យវ័យក្មេង និងផ្តល់នូវការសិក្សាស្វែងយល់ដ៏យូរអង្វែងលើវិស័យយានយន្តប្រទេសកម្ពុជា។

យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន RMAC ក្នុងការចែកចាយម៉ាកល្បីៗលើសាកលក្នុងប្រទេសកម្ពុជាបានបង្ហាញពី ការពង្រឹងទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនវិស័យយានយន្តល្បីៗ។ ផ្នែកគ្រឿងចក្រកសិកម្ម និងបរិក្ខារធុនធ្ងន់របស់ក្រុមហ៊ុន RMAC ថ្មីៗនេះបានទទួលពានរង្វាន់ "ពានរង្វាន់ John Deere Outstanding Dealer Awards " និង "JCB Global Best Digital Innovation Award" ។ យើងជាជម្រើសនៃដៃគូដ៏ល្អនៅក្នុងប្រទេសកម្ពុជាសម្រាប់ម៉ាកយីហោអន្តរជាតិ ជាមួយនឹងឱកាសកាន់តែខ្ពស់ដែលត្រូវបានបណ្តាក់ទុននាពេលអនាគត។ ការវិនិយោគថ្មីៗទៅលើម៉ាករបស់ក្រុមហ៊ុន Stellantis Group (Jeep & RAM) គឺជាសក្ខីភាពនៃភាពជាដៃគូដែលកំពុងពង្រីកទាំងនេះ។

ក្រុមហ៊ុន RMAC ត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនដ៏ឆ្នើមមួយក្នុងនាមជាក្រុមហ៊ុនដែលមានការអនុលោមទៅតាមច្បាប់ តាមកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនដើម្បីសម្រេចបាននូវកាតព្វកិច្ចពន្ធ និងអាករទាំងអស់។

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន RMAC ក្នុងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រជាជនកម្ពុជាផងដែរនោះ ក្រុមហ៊ុន RMAC បានធ្វើការជ្រើសរើសបុគ្គលិកថ្មីច្រើនជាង ២០០ នាក់ក្នុងឆ្នាំ២០២៤ ហើយបានរួមចំណែកក្នុងការផ្តល់ឱកាសបណ្តុះបណ្តាលជាច្រើនដល់បុគ្គលិកដែលមានស្រាប់របស់យើង។ ក្រុមហ៊ុន RMAC ទទួលបានពានរង្វាន់ បី(០៣)ឆ្នាំជាប់ៗគ្នា ដែលជាពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតដើម្បីធ្វើការនៅអាស៊ី សម្រាប់ឆ្នាំ២០២៤" ដោយ HR Asia ដែលបង្ហាញពីលទ្ធផលដ៏ល្អដែលទទួលបានពីទស្សនវិស័យការចូលរួមរបស់បុគ្គលិក។

ក្រុមហ៊ុន RMAC ខិតខំជំរុញគំនិតផ្តួចផ្តើមស្តីពីទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) ដែលមានឥទ្ធិពល។ ក្រុមហ៊ុន RMAC បានចូលរួមយ៉ាងសកម្មក្នុងការបរិច្ចាគដល់ (មន្ទីរពេទ្យគន្ធបុប្ផា) និងក្នុងអំឡុងពេលដំណើរកម្សាន្ត Ford Adventure ក៏បានរួមចំណែកដល់គម្រោងប្រកបដោយនិរន្តរភាពជាមួយនឹងការដាំដើមឈើជាង ១.០០០ ដើមនៅក្នុងខេត្តសៀមរាប ។

ជាកិច្ចបញ្ចប់ ខ្ញុំចង់កត់សម្គាល់នូវសេចក្តីសោមនស្សរបស់ខ្ញុំចំពោះការខិតខំប្រឹងប្រែង និងការប្រឹក្សាយោបល់ដែលផ្តល់ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន RMAC និងសូមអរគុណដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ក្រុមហ៊ុន RMAC ទាំងអស់ សម្រាប់ការពង្រីកអាជីវកម្មបន្ថែមទៀត និងបង្កើនការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ចំពោះព្រះរាជាណាចក្រកម្ពុជា។

យើងកំពុងទន្ទឹងរង់ចាំនៅឆ្នាំ២០២៥ ដើម្បីពង្រីកអាជីវកម្មរបស់យើងបន្ថែមទៅមុខទៀតតាមរបៀបនិរន្តរភាព។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក R M A (CAMBODIA) PLC. KINGDOM OF CAMBODIA

**លោក** Kevin Whitcraft

**ប្រធានក្រុមប្រឹក្សាភិបាល**

កាលបរិច្ឆេទ៖ ០២ មេសា ២០២៥

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

វិនិយោគិនជាទីគោរព

ដូចដែលយើងបានឆ្លុះបញ្ចាំងនៅឆ្នាំ២០២៤ ខ្ញុំចង់បង្ហាញនូវគន្លឹះខ្លះៗអំពីប្រតិបត្តិការរបស់ក្រុមហ៊ុនយើងខ្ញុំ ស្របពេលជាមួយនឹងសេដ្ឋកិច្ចប្រទេសកម្ពុជានៅតែបន្តជួបការលំបាក និងការរីកចម្រើនក្នុងឧស្សាហកម្មរថយន្ត។

ឧស្សាហកម្មរថយន្តនៅកម្ពុជាបានកើនឡើងបន្តិចចំនួន+៤%នៅក្នុងឆ្នាំ២០២៤ ធៀបនឹងការធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងឆ្នាំ២០២៣ ដោយសារភាពមិនចិតថេរនៃសេដ្ឋកិច្ច អត្រាការប្រាក់ធ្លាក់ចុះ និងការប្រែប្រួលនៃចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ បានបង្ហាញពីបញ្ហាប្រឈមយ៉ាងខ្លាំង។ ទោះបីជាយ៉ាងណាក៏ដោយ ការកើនឡើងជាលំដាប់នៃទំនុកចិត្តរបស់អ្នកប្រើប្រាស់ត្រូវបានបង្ហាញឱ្យឃើញថាក្នុងអំឡុងពេលពាក់កណ្តាលឆមាសទីពីរនៃឆ្នាំនេះ ការលក់រថយន្តគឺមានការកើនឡើង។

ទោះបីជាមានឧបសគ្គទាំងនេះក៏ដោយ ខ្ញុំមានមោទនភាពក្នុងការប្រកាសថាក្រុមហ៊ុនរបស់យើងបានផ្តល់នូវលទ្ធផលហិរញ្ញវត្ថុដ៏គួរឱ្យសរសើរ ដែលជាសក្ខីភាពដល់អតិថិជនដែលតែងតែគាំទ្រដល់យើងតាំងពីដើមរហូតមក និងការវិវត្តន៍របស់យើងឱ្យទាន់តាមស្ថានភាពសង្គម។

លទ្ធផលហិរញ្ញវត្ថុរបស់យើងនៅឆ្នាំនេះ ត្រូវបានគាំទ្រដោយគំនិតផ្តួចផ្តើមយុទ្ធសាស្ត្រជាច្រើន។ យើងបានពង្រីកការបង្ហាញរថយន្ត Ford Territory ដោយការណែនាំនៃ Territory Dark Edition ដ៏គួរឱ្យរំភើប។ ផ្នែក Changan របស់យើង បានណែនាំរថយន្តអគ្គិសនីចំនួន ២គ្រឿង ក្រោមម៉ាក Deepal (Deepal S07 & L07) ហើយយើងបានពង្រីកវិសាលភាពរបស់យើងដោយបើកសម្ពោធម៉ាក Jeep & RAM ដែលជាម៉ាករបស់ក្រុមហ៊ុន Stellantis Group។ កិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងនេះបង្ហាញជំហរយ៉ាងរឹងមាំរបស់យើងសម្រាប់ការរីកចម្រើននាពេលអនាគត។

ទោះជាយ៉ាងណាក៏ដោយ យើងពុំទាន់ជួបការគាប់ចិត្តនៅឡើយទេ ហើយនៅតែបន្តសម្លឹងទៅមុខ។ ក្រុមការងាររបស់យើងទទួលស្គាល់ថាឧស្សាហកម្មនេះនៅតែបន្តវិវឌ្ឍក្នុងល្បឿនយ៉ាងលឿន ហើយយើងត្រូវបន្តនាំមកនូវនវានុវត្តន៍ថ្មី និងសម្របខ្លួនជានិច្ច ដើម្បីរក្សាការប្រកួតប្រជែងរបស់យើង។ នៅក្នុងឆ្នាំ២០២៥ យើងបានរៀបចំគម្រោងវិនិយោគបន្ថែមទៅលើសម្ភារៈបរិក្ខារ និងមជ្ឈមណ្ឌលសេវាកម្មថ្មីៗ ដើម្បីពង្រឹងសមត្ថភាពឌីជីថលរបស់យើង និងស្វែងរកឱកាសអាជីវកម្មថ្មីៗដើម្បីបង្កើនបទពិសោធន៍ដល់អតិថិជន និងបង្កើតតម្លៃសម្រាប់ម្ចាស់ភាគហ៊ុនរបស់យើង។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងយ៉ាងជ្រាលជ្រៅ ចំពោះអតិថិជនដ៏ស្មោះត្រង់របស់យើងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបុគ្គលិកដែលខិតខំប្រឹងប្រែងរបស់យើង ហើយសូមថ្លែងអំណរគុណដល់ម្ចាស់ភាគហ៊ុនរបស់យើងទាំងអស់សម្រាប់ការជឿទុកចិត្ត និងការគាំទ្ររបស់អ្នក។ យើងប្តេជ្ញាចិត្តក្នុងការតបស្នងនូវគុណតម្លៃរយៈពេលវែង និងការផ្តល់ជូនសហគមន៍របស់យើងនូវផលផ្លែនៃភាពជោគជ័យរបស់យើង ហើយទន្ទឹងរង់ចាំក្នុងការស្វែងរកដំណើរឆ្ពោះទៅមុខជាមួយគ្នា។

សូមអរគុណចំពោះការបន្តគាំទ្ររបស់អ្នកទាំងអស់គ្នាគន្លងមក។

**លោក ខន សាំខ**
**នាយកប្រតិបត្តិក្រុមហ៊ុន អ រិម អេ (ខេមបូឌា)**
កាលបរិច្ឆេទ៖ ០២ មេសា ២០២៥

# មាតិកា


ចក្ខុវិស័យ ........ ២

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ៣

ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ........ ៤

សមាជិកក្រុមប្រឹក្សាភិបាល ........ ៦

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ ៧

សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ........ ១១

ផ្នែកទី១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ........ ១៤

ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ........ ១៤

ខ. សកម្មភាពអាជីវកម្ម ........ ១៤

គ. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ ........ ១៥

ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយ ........ ១៥

ង. ស្ថានភាពទីផ្សារ ........ ២៣

ច. សកម្មភាពប្រកួតប្រជែង ........ ២៣

ឆ. គ្រោងការណ៍អនាគត ........ ២៣

ជ. កត្តាហានិភ័យ ........ ២៤

ផ្នែកទី២. ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ២៥

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ២៥

ខ. រចនាសម្ព័ន្ធប្រាក់ចំណូល ........ ២៥

ផ្នែកទី៣. ព័ត៌មានស្តីអំពីអភិបាលកិច្ចរបស់ក្រុមហ៊ុន ........ ២៦

ផ្នែកទី៤. ព័ត៌មានស្តីអំពីការលក់ដមូលបត្រ និងម្ចាស់ភាគហ៊ុន ........ ២៩

ក. ព័ត៌មានស្តីពីមូលបត្រ ........ ២៩

ខ. តម្លៃមូលបត្រ និងបរិមាណនៃការលក់ ........ ៣០

គ. ការគ្រប់គ្រងម្ចាស់ភាគហ៊ុន (៣០% ឬលើសពី៣០%)....................................................................................៣០

ផ្នែកទី៥ - របាយការណ៍សវនកម្មផ្ទៃក្នុងស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន..........................................៣១

ផ្នែកទី៦ - របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យដោយសវនករផ្ទៃក្នុង ..............................................................៣៣

ផ្នែកទី៧ - ព័ត៌មានស្តីពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍..........................................៣៤

ផ្នែកទី៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង................................................................................៣៥

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ...........................................................................................................................៣៥

ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ.........................................................................................៣៦

គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល..................................................................................៣៦

ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ .......................................................................៣៧

ង. ផលប៉ះពាល់នៃអតិផរណា ..............................................................................................................................៣៧

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល....................................................៣៧

ឆ. ព្រឹត្តិការណ៍សំខាន់ៗ.........................................................................................................................................៣៧

ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ...................................................................................៣៨

ឧបសម្ព័ន្ធ៖ របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ (បានភ្ជាប់ជាមួយរបាយការណ៍ប្រចាំឆ្នាំ)

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| | |
|---|---|
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ** | អ អិម អេ (ខេមបូឌា) ម.ក |
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង** | RMA (CAMBODIA) PLC |
| **លេខកូដស្តង់ដារ** | KH2000121A44 |
| **អាសយដ្ឋាន** | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៨ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| **លេខទូរស័ព្ទ** | +៨៥៥ (0) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៨៧ |
| **លេខទូរសារ** | +៨៥៥ (0) ២៣ ៨២៦ ៧៥២ |
| **គេហទំព័រ** | www.cambodia.rmagroup.net |
| **អ៊ីម៉ែល** | saing.ngorn@rmagroup.net |
| **លេខចុះបញ្ជីក្រុមហ៊ុន** | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| **លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន** | ០០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| **ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ** | លោក ងន សាំង |
| **លេខាធិការក្រុមហ៊ុន** | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, TCM, JCB, FUSO, John Deere, Jaguar Land Rover, MS Pallet, Megger & Sebar, GenieGrips, Hako, PowerBoss, AJAX, Piaggio, Changan, Haulotte, សេវាកម្មក្រោយការលក់ Mercedes-Benz និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ)។ រថយន្តម៉ាក Jeep និង RAM មកពីគ្រុបរថយន្ត Stellantis ដែលបានបន្ថែមនៅក្នុងឆ្នាំ២០២៤។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងការតម្លើងដំបូងគេបង្អស់។ ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់ភាគហ៊ុន | ស្នូលនៃអាជីវកម្ម | ថ្ងៃចុះបញ្ជីក្រុមហ៊ុន | អាសយដ្ឋាន |
|---|---|---|---|---|---|---|
| ១ | Clipper Holding Ltd | ក្រុមហ៊ុនហូលឌីង នៃ ក្រុមហ៊ុន អ អិម អេ គ្រុប | ៩៩,៩% | ក្រុមហ៊ុនកាន់កាប់ | ០៥ តុលា ២០០៧ | 31/F., Tower Two Times Square 1 Matheson Street, Causeway Bay HONG KONG |

## ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយ

### ព្រឹត្តិការណ៍តាំងពិពណ៌



**ពិធីសម្ពោធពិព័រណ៍ធុរកិច្ចក្រុមហ៊ុន អ អិម អេ (ខេមបូឌា)**

កម្មវិធីនៃការតាំងពិព័រណ៌នេះត្រូវបានរៀបចំឡើងចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៤ ដែលជាការដាក់តាំងបង្ហាញលើកដំបូងបំផុតរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ដើម្បីបង្ហាញផលិតផល និងសេវាកម្មទាំងអស់របស់ក្រុមហ៊ុន អ អិម អេ និងដៃគូសហការរបស់ អ អិម អេ នៅក្នុងប្រទេសកម្ពុជា។ ព្រឹត្តិការណ៍នេះបានប្រារព្ធឡើងរយៈពេល៣ថ្ងៃ នៅមជ្ឈមណ្ឌលពិព័រណ៍ ព្រេមៀ សែនសុខ។



**ដឹ ព្រេមៀ សែនសុខ AUTOSHOW ២០២៤**

កាលពីថ្ងៃទី២៧ ខែមេសា ក្រុមហ៊ុនហ្វដ ខេមបូឌា បានចូលរួមនៅក្នុងព្រឹត្តិការណ៍ប្រចាំឆ្នាំនេះគឺ The Premier Sen Sok Autoshow 2024 ដែលធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តម ហ៊ុន ម៉ានី។ ព្រឹត្តិការណ៍នេះគឺជាឱកាសសម្រាប់ផ្នែកក្រុមហ៊ុន RMAC ដើម្បីបង្ហាញរថយន្ត Ford Ranger Wildtrak, Ford Ranger Raptor, Ford Territory, Ford Everest និងរថយន្ត Ford Tourneo ដ៏ប្រណិត។

**FORD CAMBODIA AT RMA**
**EXPO 2024 IN SIEM REAP PROVINCE**



### **ការពិព័រណ៍ធុរកិច្ច RMAC នៅខេត្តសៀមរាប**

ចាប់ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៦ ខែវិច្ឆិកា ក្រុមហ៊ុន RMAC បានរៀបចំកម្មវិធី ពិព័រណ៍ធុរកិច្ច អ អិ អេ ខេមបូឌា (RMA Cambodia EXPO) នៅខេត្តសៀមរាប។ ស្តង់តាំងពិព័រណ៍របស់ហ្វដ ខេមបូឌា បានដាក់តាំងបង្ហាញនូវស៊េរីរថយន្តស៊េរីចុងក្រោយបង្អស់រួមមាន Fird Ranger XLT, Ford Ranger WildTrak, Rord Ranger Raptor, Ford Everest និង Ford Territory។ ផ្នែក John Deere ក៏បានបង្ហាញត្រាក់ទ័រដ៏ល្បីរបស់ខ្លួនដល់សាធារណជនផងដែរ។

## ពិធីសម្ពោធផលិតផល




### **ពិធីសម្ពោធរថយន្ត** FORD TERRITORY DARK EDITION

នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៤ ហ្វដ ខេមបូឌា បានសម្ពោធរថយន្ត Ford Territory Dark Edition ថ្មីទាំងអស់ នៅចំពោះមុខភ្ញៀវចំនួន ២៥០០ នាក់។ រថយន្តថ្មីនេះបានភ្ជាប់ជាមួយនឹងការរចនាថ្មី ជាមួយនឹងផ្នែកខាងក្នុងពណ៌ខ្មៅរលោង ដែលបានធ្វើឲ្យទស្សនិកជន មានការចាប់អារម្មណ៍។ យើងរំពឹងថានឹងមានភាពជោគជ័យផ្នែកពាណិជ្ជកម្មខ្លាំងចំពោះម៉ូដែលថ្មីនេះ។




### **ការបើកសម្ពោធរថយន្តស៊េរីថ្មី** FORD RANGER

ព្រឹត្តិការណ៍នេះ ត្រូវបានរៀបចំឡើងនៅ ដឹ ព្រេមៀ សេនធ័រ សែនសុខ នៅចំពោះមុខភ្ញៀវដែលបានអញ្ជើញចំនួន ២,០០០ នាក់ និងវត្តមានរបស់លោកDavid Jeffrey (ជានាយកប្រតិបត្តិទីផ្សារអ្នកចែកចាយរបស់Ford AP)។




**សូមណែនាំរថយន្តថ្មីម៉ាក** RANGE ROVER SV PHEV

ព្រឹត្តិការណ៍នេះ បានធ្វើឡើងនៅគេហដ្ឋានប្រណីត «Norea Cove»។ ការសម្តែងនេះបានបង្ហាញពីភាពប្រណិត និងការច្នៃប្រឌិតរបស់ Land Rover ។




**ការសម្ពោធរថយន្តស៊េរីថ្មីម៉ាក** FUSO 1.5T FE71

សេចក្តីណែនាំអំពីទីផ្សារប្រទេសកម្ពុជា រថយន្តដឹកទំនិញ FUSO ស៊េរីថ្មីដែលល្បីល្បាញដោយសារភាពធន់ និងការដំណើរការរបស់វា




**ការសម្ពោធជាផ្លូវការ នៃរថយន្តម៉ាក**

CHANGAN DEEPAL EV

ថ្ងៃទី២៣ ខែសីហា ក្រុមហ៊ុន RMAC បានណែនាំរថយន្តអគ្គិសនីចំនួនពីរម៉ូដែល Changan Deepal L07 និង S07 ដោយមោទនភាព។ ម៉ូដែលទាំងពីរនេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងដំណើររបស់ប្រទេសកម្ពុជាឆ្ពោះទៅរកការច្នៃប្រឌិតបច្ចេកវិទ្យា និងការដឹកជញ្ជូនប្រកបដោយនិរន្តរភាព



## **សម្ភោធរថយន្ត** FUSO FIRST MOVING DAIRY QUENING **នៅកម្ពុជា**

កាលពីថ្ងៃទី០៩ ខែសីហា FUSO Canter FE71 ត្រូវបានដាក់លក់ជាផ្លូវការក្នុងប្រទេសកម្ពុជា ជារថយន្ត Dairy Queen Icream ដំបូងបង្អស់ក្នុងប្រទេស។ វាបង្ហាញពីសមត្ថភាពពិសេសរបស់រថយន្ត FUSO ដែលអាចបទបែនបានតាមបំណង។

# ទំនាក់ទំនងសាធារៈ



## **ក្រុមហ៊ុន RMAC ជាដៃគូសហការជាមួយក្រសួងការងារ**

កាលពីថ្ងៃទី០៩ ខែកញ្ញា ក្រុមហ៊ុន RMAC បានចុះហត្ថលេខា លើអនុស្សរណៈ នៃការយោគយល់គ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ស្តីពី "កិច្ចសហប្រតិបត្តិការលើវិស័យការងារ សន្តិសុខសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈកម្មវិធីហ្វឹកហ្វឺនកូនជាង ការបណ្តុះបណ្តាលតាមបច្ចេកវិទ្យាចុងក្រោយ និងសេវាការងារសាធារណៈ" ក្រោមអធិបតីភាពឯកឧត្តម ហេង សួរ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។




នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ RMAC និង Bendigo Kangan Institute (BKI) Group នៃប្រទេសអូស្ត្រាលីបានចុះអនុស្សរណៈ នៃការ យោគយល់ ដើម្បីបង្កើតមជ្ឈមណ្ឌលឧត្តមភាពយានយន្តនៅកម្ពុជា ក្រោមការសហការគាំទ្រ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ផ្នែកបរិក្ខារថ្មី



### ការត្រួតពិនិត្យមុនពេលចែកចាយរបស់ FORD (PDI) និងការបើកដំណើរការទីស្នាក់ការដឹកជញ្ជូន

ក្រុមហ៊ុន Ford សាខាបឹងបៃតងបានរៀបចំពិធីសម្ពោធជាផ្លូវការនៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២៤។ រោងចក្រនេះមានទំហំ ៦,៥០០ ម៉ែត្រការ៉េ ហើយនឹងផ្តល់សេវាកម្ម PDI លំដាប់ពិភពលោក និងសេវាកម្មដឹកជញ្ជូនដល់អតិថិជន Ford របស់យើង។

### ការបើកសម្ពោធអគារតាំងបង្ហាញថ្មី



កាលពីថ្ងៃទី០៩ ខែកញ្ញា ក្រុមហ៊ុន RMAC បានបើកសម្ពោធជាផ្លូវការនូវបន្ទប់តាំងបង្ហាញថ្មី សម្រាប់ផ្នែករថយន្តកសិកម្ម (John Deere) និងបរិក្ខារធុនធ្ងន់ (JCB) នៅលើផ្លូវជាតិលេខ ៦។ ព្រឹត្តិការណ៍នេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកស្រី Yajun Bian នាយកទីផ្សារ និងលក់ John Deere និង លោក ឯន សាំង ជានាយកប្រតិបត្តិនៃក្រុមហ៊ុន RMAC។




### ការបើកសម្ពោធអគារតាំងបង្ហាញរថយន្តម៉ាក JEEP និង RAM

នៅថ្ងៃទី ០៨ ខែវិច្ឆិកា RMAC បានបើកសម្ពោធជាផ្លូវការនូវអគារតាំងបង្ហាញថ្មី និងម៉ូដែលរថយន្ត ALL-New Jeep Wrangler Rubicon ។ ម៉ាករថយន្ត Jeep ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន Stellantis Group ។




## ការបើកសម្ពោធអគារ JOHN DEERE 3S នៅខេត្តត្បូងឃ្មុំ

នៅថ្ងៃទី១៦ ខែធ្នូ RMAC បានបើកសម្ពោធអគារ John Deere 3S ថ្មីរបស់ខ្លួននៅក្នុងខេត្តត្បូងឃ្មុំ។ កម្មវិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ប៉ែន កុសល្យ អភិបាលនៃ គណៈអភិបាលខេត្ត និងលោក ងន សាំង នាយកប្រតិបត្តិ RMAC ។

# ផ្នែកថ្មី




## បើកដំណើរការសេវាកម្មក្រោយការលក់ផ្តាច់មុខជាមួយ JEEP និង RAM

ថ្ងៃទី១២ ខែសីហា ផ្នែក RMAC Stellantis បានប្រកាសទទួលថា បានធានាសិទ្ធិផ្តាច់មុខក្នុងការផ្តល់សេវាថែទាំលើរថយន្ត Jeep និង RAM brnads នៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន RMAC ប្តេជ្ញាក្នុងការផ្តល់សេវាកម្មលំដាប់កំពូល តាមរយៈគ្រឿងបរិក្ខារទំនើបៗ និងអ្នកបច្ចេកទេសដែលមាន ការបណ្តុះបណ្តាលខ្ពស់។

# ពានរង្វាន់

## CAMBODIA VIN សម្រាប់រថយន្ត FORD




លេខ VIN លើរថយន្តសម្រាប់គម្រោង IKD-1 បង្ហាញថារថយន្តនេះត្រូវបានដំឡើងនៅក្នុងប្រទេសកម្ពុជា។ ប្រសិនបើរថយន្តត្រូវបាននាំចេញ ប្រទេសដែលនាំចូលអាចទទួលស្គាល់ប្រភពដើមនៃរថយន្ត ថាជារបស់(កម្ពុជា) ដោយស្កេនលេខ VIN ។

ក្រុមហ៊ុន អ អិម អេ ខេមបូឌា មានមោទនភាពក្នុងការក្លាយជា ក្រុមហ៊ុនដំឡើងរថយន្តដំបូងគេក្នុងប្រទេសកម្ពុជា ដោយសម្រេចបានការទទួលស្គាល់ លេខVIN ទូទាំងពិភពលោក ខណៈដែលរថយន្តត្រូវបានផលិតនៅក្នុងប្រទេសកម្ពុជា។




## ពានរង្វាន់សម្រាប់ការច្នៃប្រឌិតឌីជីថលនៃ JCB GLOBAL

ផ្នែក បរិក្ខារធុនធ្ងន់ (HED) កម្ពុជា បានទទួលពានរង្វាន់ការច្នៃប្រឌិតឌីជីថល ក្នុងការទទួលស្គាល់សម្រាប់ការខិតខំប្រឹងប្រែងឥតឈប់ឈរ ដើម្បីទទួលយកការផ្លាស់ប្តូរឌីជីថល និងការប្រើប្រាស់ឧបករណ៍ឌីជីថល។




## 2024 HR ASIA AWARDS

នៅថ្ងៃទី២៧ ខែកញ្ញា ក្រុមហ៊ុន RMAC បានទទួលពានរង្វាន់ដ៏ មានកិត្យានុភាពចំនួនពីរសម្រាប់ "ក្រុមហ៊ុន ល្អបំផុតដើម្បីធ្វើការនៅអាស៊ី" និង "ក្រុមហ៊ុនដែលយកចិត្តទុកដាក់បំផុត" ។ នេះឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំក្រុមហ៊ុនរបស់យើងក្នុងការលើកកម្ពស់វប្បធម៌កន្លែងធ្វើការជាវិជ្ជមាន និងការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅ ចំពោះសុខុមាលភាពរបស់បុគ្គលិកនៅក្នុងប្រទេសកម្ពុជា។




## ការចូលរួមចំណែកទានក្នុងការអភិវឌ្ឍវិស័យមូលបត្រ

នៅថ្ងៃទី២៩ ខែតុលា RMAC ទទួលបានពាន រង្វាន់ក្នុងការបំពេញការងារឆ្នើម និងការយកចិត្តទុកដាក់ ក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅ កម្ពុជា។ RMAC ទទួលបានពានរង្វាន់ដ៏មាន កិត្យានុភាពគឺ "បណ្ណសសើរការបង្ហាញព័ត៌មាន សាជីវកម្មឆ្នើមប្រចាំឆ្នាំ២០២៤" និង "លិខិតថ្លែងអំណរគុណសម្រាប់ការចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុវិស័យមូលបត្រ"។




## ការទទួលស្គាល់ពានរង្វាន់អ្នកចែកចាយឆ្នើម សម្រាប់ JOHN DEERE កម្ពុជា

នៅក្នុងខែធ្នូ RMAC ជាក្រុមហ៊ុនដែលទទួលបានសិទ្ធិចែកចាយពីផលិតផល John Deere បានសម្រេចនូវព្រឹត្តិការណ៍ដ៏សំខាន់មួយ ដោយទទួលបានរង្វាន់ដ៏មានកិត្យានុភាពពីរគឺ "JDA Outstanding Dealer Award" និង "A&CS High Performance Dealer Award" !

## ព្រឹត្តិការណ៍ CSR




### ការបរិច្ចាគក្នុងព្រឹត្តិការណ៍រត់ដើម្បីជីវិត

កម្មវិធីសប្បុរសធម៌មួយត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់លោក ងន សាំង ជានាយកប្រតិបត្តិ ដែលមានការចូលរួមពីបុគ្គលិករបស់ ក្រុមហ៊ុន RMAC។ ថវិកាដែលរៃអង្គាសបាន ត្រូវបានប្រគល់ជូនមន្ទីរពេទ្យគន្ធបុប្ផាទី៣ (មន្ទីរពេទ្យជ័យវរ្ម័នទី៧) ខេត្តសៀមរាប។




### ការដាំដើមឈើនៅខេត្តសៀមរាប

នៅថ្ងៃទី២១ ខែកញ្ញា ក្រុមហ៊ុន RMAC និងបុគ្គលិករបស់ក្រុមហ៊ុន បានដាំដើមឈើចំនួន ១,៣៥០ដើម នៅតាមបណ្តោយផ្លូវជាតិលេខ៦ ក្នុងខេត្តសៀមរាប។ ព្រឹត្តិការណ៍នេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម យន់ លីនណេ អភិបាលរងខេត្តសៀមរាប និងលោក សាំង ងន ជានាយកប្រតិបត្តិ នៃក្រុមហ៊ុន RMAC។

**FORD ADVENTURE 2024**
**TRIP 1 & TRIP 2 COMPLETED**



**ដំណើរកម្សាន្ត និងការប្រគល់មកវិញនូវព្រឹត្តិការណ៍សហគមន៍សម្រាប់ FORD**

ដំណើរកម្សាន្តរបស់រថយន្ត Ford Adventure ចំនួនពីរត្រូវបានធ្វើឡើងនៅថ្ងៃទី ១២-១៥ និង ១៩-២២ ខែធ្នូ ឆ្លងកាត់ព្រំដែនទៅកាន់ប្រទេសឡាវ។ ក្បួនរថយន្តបានស្វាគមន៍រថយន្តជាង២៥០គ្រឿង និងអ្នកចូលរួមចំនួន១.០០០នាក់ ។ ការចែកអំណោយដល់គ្រួសារដែលមានការខ្វះខាតនៅតាមជនបទចំនួន ៤០០ គ្រួសារ។

## ង. ស្ថានភាពទីផ្សារ

ទីផ្សាររថយន្តនៅកម្ពុជាសម្រាប់ឆ្នាំ ២០២៤ មានការកើនឡើងចំនួន ៤% បើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួនប្រមាណ៥៣.០០០គ្រឿង ទាំងរថយន្តថ្មី និងរថយន្តប្រើហើយ ដែលត្រូវបានលក់ និងចុះបញ្ជី ដែលមានចំនួនប្រមាណ ៥១.០០០គ្រឿង បើធៀបនឹងឆ្នាំ២០២៣។ ការលក់រថយន្តថ្មីមានចំនួន ២៧,០០០ គ្រឿង ដែលបានកើនឡើងចំនួន ១៣% បើធៀបនឹងឆ្នាំ២០២៣។ នៅក្នុងឆ្នាំ២០២៤ ទីផ្សាររថយន្តថ្មីបានកើនឡើង ៥១% នៃទីផ្សារសរុប ដោយមានការឈានមុនពី ៤៧% នៅឆ្នាំ២០២៣។

## ច. សកម្មភាពប្រកួតប្រជែង

ការប្រកួតប្រជែងទីផ្សាររថយន្តនៅកម្ពុជាបានកើនឡើងនៅឆ្នាំ២០២៤ ជាមួយនឹងការមកដល់នៃម៉ាកថ្មីដែលសំខាន់មកពីប្រទេសចិន។ ក្រុមហ៊ុនផលិតឧបករណ៍ដើមរបស់ចិនត្រូវបានគេប៉ាន់ប្រមាណថាតំណាងឱ្យ ៣០% នៃទីផ្សាររថយន្តថ្មីនៅចុងឆ្នាំ ២០២៤។ ទីផ្សារក៏កំពុងផ្លាស់ប្តូរនៅក្រោមកំណើនដ៏សំខាន់នៃរថយន្តអគ្គិសនីដែលមានប្រហែល ៨% នៃទីផ្សាររថយន្តថ្មីដែលមានចំនួន ២.២០០ គ្រឿង។

## ឆ. គ្រោងការណ៍អនាគត

ក្រុមហ៊ុននឹងខិតខំឱ្យក្លាយជាអ្នកផ្គត់ផ្គង់ឈានមុខគេនៃរថយន្ត សំណង់ គ្រឿងចក្រកសិកម្ម និងឧបករណ៍សម្រាប់លើកសម្ភារៈលំដាប់ពិភពលោកនៅកម្ពុជា។ តាមរយៈការនាំចូលនូវម៉ាកយីហោល្បីៗ គោលដៅរបស់ក្រុមហ៊ុនគឺធ្វើជាអ្នកផ្គត់ផ្គង់ឆ្ពោះមុខនៃផលិតផលនីមួយៗទាំងបីប្រភេទ ខណៈពេលដែលកំពុងផ្តល់សេវាកម្មលំដាប់ពិភពលោក ទៅលើសេវាកម្មក្រោយការលក់ និងសេវាកម្ម ព្រមទាំងធានានូវការគាំទ្រការធានាពេញលេញនៃផលិតផលដែលបានលក់។

ក្រុមហ៊ុនមានបំណងបន្តក្លាយជាអ្នកនាំមុខគេក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការវិនិយោគលើសម្ភារៈបរិក្ខារ និងមជ្ឈមណ្ឌលសេវាកម្មថ្មីៗ ពង្រឹងសមត្ថភាពឌីជីថល និងស្វែងរកឱកាសអាជីវកម្មថ្មីៗ ដើម្បីបង្កើនបទពិសោធន៍អតិថិជន និងបង្កើតតម្លៃសម្រាប់ម្ចាស់ភាគហ៊ុនរបស់យើង។

### ជ. កត្តាហានិភ័យ

ឧស្សាហកម្មយានយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបរិក្ខារធុនធ្ងន់ជាទូទៅប្រឈមនឹងកត្តាហានិភ័យជាក់លាក់មួយចំនួន។ តាមទស្សនៈសាជីវកម្ម ឧស្សាហកម្មទាំងនេះពឹងផ្អែកលើការសមត្ថភាពរបស់អ្នកផ្គត់ផ្គង់ក្នុងការផ្គត់ផ្គង់ទាន់ពេលវេលា ប្រកបដោយគុណភាពដែលឆ្លុះបញ្ចាំងពីចំណូលចិត្តរបស់អតិថិជន។

ហានិភ័យដែលកើតឡើងពីអតិថិជនគឺចំណូលចិត្តដែលមានការផ្លាស់ប្តូរទៅតាមបរិបទសង្គម ដោយការផ្លាស់ប្តូរនេះទទួលបានការជះឥទ្ធិពលពីវប្បធម៌ និងបរិស្ថាន។

## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗក្នុងឆ្នាំ២០២៤ រួមមាន៖

ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖

សម្រាប់ឆ្នាំ២០២៤ រថយន្តម៉ាក Ford នៅតែរក្សាភាពឈានមុខគេក្នុងទីផ្សារ។ រថយន្តម៉ាក Ford Ranger នៅតែបន្តជារថយន្តលំដាប់ទីមួយដែលលក់ដាច់ជាងគេក្នុងចំណោមទីផ្សាររថយន្តថ្មីក្នុងប្រទេសកម្ពុជា។

**គ្រឿងចក្រម៉ាក John Deere៖**

យោងតាមប្រភពផ្ទៃក្នុងរបស់យើង John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធន់ធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**លទ្ធផលហិរញ្ញវត្ថុ៖**

ប្រាក់ចំណូលប្រចាំឆ្នាំ២០២៤ គឺចំនួន ១.៦៣១ ប៊ីលលានរៀល ដែលជាមានការថយចុះចំនួន -៩,៥% បើប្រៀបធៀបទៅនឹងចំណូលឆ្នាំ២០២២៣។ ប្រាក់ចំណេញពីឆ្នាំ២០២៤ បន្ទាប់ពីការបង់ពន្ធមានចំនួន ៦៧,៦ ប៊ីលលានរៀល។

ក្រុមហ៊ុន RMAC បានធ្វើការវិនិយោគនូវសាច់ប្រាក់សុទ្ធចំនួន ៩,៧ ប៊ីលលានរៀលក្នុងរយៈពេល១២ខែ នៃឆ្នាំ២០២៤ ដោយរាប់បញ្ចូលទាំងការសាងសង់អគារតាំងបង្ហាញថ្មី ការទិញរថយន្តថ្មី និងគ្រឿងបរិក្ខារបន្ថែម សម្រាប់ប្រតិបត្តិការផ្សេងៗ។

### ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកជាច្រើនរួមមាន Ford, Changan, Jeep & RAM, Land Rover, John Deere, TCM, JCB, FUSO, MS Pallet, Megger & Sebar, Hako, AJAX, Haulotte, សេវាកម្មក្រោយការលក់ម៉ាក Mercedes-Benz និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ). រថយន្តម៉ាក Jeep និង RAM មកពីគ្រុបរថយន្ត Stellantis ដែលបានបន្ថែមនៅក្នុងឆ្នាំ២០២៤។

## ផ្នែកទី៣.- ព័ត៌មានស្ដីអំពីអភិបាលកិច្ចរបស់ក្រុមហ៊ុន

### ក. រចនាសម្ព័ន្ធក្រុមហ៊ុន



## ខ. ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | លោក Kevin Robert Whitcraft | ប្រធានក្រុមប្រឹក្សាភិបាល | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២៥ |
| ២ | លោក Thomas Arthur Whitcraft | អភិបាលមិនប្រតិបត្តិ | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២៥ |
| ៣ | លោក ងន សាំង | អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ | ២៣ មីនា ២០១៦ | ២៨ កក្កដា ២០២៥ |
| ៤ | លោក Ith Vichit | អភិបាលឯករាជ្យ | ២៩ កក្កដា ២០១៩ | ២៨ កក្កដា ២០២៥ |
| ៥ | លោក Wiedmann Apiwat Christian | អភិបាលមិនប្រតិបត្តិ | ៣១ ឧសភា ២០២៣ | ២៨ កក្កដា ២០២៥ |

លេខាធិការក្រុមហ៊ុន៖ លោក មាស សុវណ្ណ នាយកគ្រប់គ្រងផ្នែកច្បាប់ និងអនុលោមភាព។

## គ. មន្ត្រីជាន់ខ្ពស់

សមាសភាពមន្ត្រីជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | លោក ងន សាំង | ប្រុស | នាយកប្រតិបត្តិ |
| ២ | លោក សេង រឹង | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក Ford |
| ៣ | លោក Erwan Soubelet | ប្រុស | នាយកហិរញ្ញវត្ថុ |
| ៤ | កញ្ញា ហ៊ុំ សោភ័ណវតី | ស្រី | ប្រធានគ្រប់គ្រងទូទៅផ្នែក JLR |
| ៥ | លោក សុខ សុន្ទរ៉ា | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកបរិក្ខារកសិកម្ម |
| ៦ | លោក តាន់ អាង | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកគ្រប់គ្រងសម្ភារៈ |
| ៧ | លោក Grant Honeyman | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកធនធានមនុស្ស |
| ៨ | លោក ឈឿន មករា | ប្រុស | ប្រធានផ្នែកភ័ស្តុភារ (Logistics) |
| ៩ | លោក មាស សុវណ្ណ | ប្រុស | លេខាធិការក្រុមហ៊ុន |
| ១០ | លោកស្រី ណាង ពិសី | ស្រី | ប្រធានផ្នែកទំនាក់ទំនងសាធារណៈ |
| ១១ | លោកស្រី សុខ ណារី | ស្រី | ប្រធានផ្នែកលទ្ធកម្ម |
| ១២ | លោក មុំ សុវណ្ណារ៉ា | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកបរិក្ខារធុនធ្ងន់ |
| ១៣ | លោក នូ ណារុណ | ប្រុស | ប្រធានគ្រប់គ្រងទូទៅ (ផ្នែកដែលត្រូវតំឡើង) |
| ១៤ | កញ្ញា វ៉ាល សុម៉ាលី | ស្រី | ប្រធានគ្រប់គ្រងទូទៅផ្នែក Changan |
| ១៥ | លោក រិទ្ធ ច័ន្ទរតនៈ | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក Mercedes Benz |
| ១៦ | លោក កែវ សុវណ្ណរិទ្ធិ | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក ឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន |

| | | | |
|---|---|---|---|
| ១៧ | លោក Aung Htun | ប្រុស | ប្រធានផ្នែកគម្រោង |
| ១៨ | លោក Krishna Bhattarai | ប្រុស | ប្រធានផ្នែកដៃគូសហការអាជីវកម្ម |
| ១៩ | លោក ផុន ឆោមឆវ៉ា | ប្រុស | ប្រធានគ្រប់គ្រងបរិស្ថាន និងសង្គម |
| ២០ | លោក ឌឹក គឹមហួរ | ប្រុស | ប្រធានផ្នែកចែកចាយ |
| ២១ | លោក ហុង សុខឃាង | ប្រុស | ប្រធានផ្នែកគាំទ្រអាជីវកម្ម និងអ្នកគ្រប់គ្រងការអភិវឌ្ឍន៍អាជីវកម្ម |
| ២២ | លោក តេង សុវ៉ាត | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកប្រតិបត្តិនៃបរិក្ខារពិសេស |

សម្គាល់៖ ព័ត៌មានលម្អិតនៃអភិបាលកិច្ចក្រុមហ៊ុនត្រូវបានភ្ជាប់ដូចនៅក្នុងឧបសម្ព័ន្ធ។

## ផ្នែកទី៤. ព័ត៌មានស្តីអំពីការលក់ដមូលបត្រ និងម្ចាស់ភាគហ៊ុន

### ក. ព័ត៌មានស្តីពីមូលបត្រ

១. ព័ត៌មានស្តីពីមូលបត្រកម្មសិទ្ធិ (សម្រាប់ក្រុមហ៊ុនបោះផ្សាយកម្មសិទ្ធិ)

- ឈ្មោះមូលបត្រកម្មសិទ្ធិ [គ្មាន]
- និមិត្តសញ្ញានៃមូលបត្រកម្មសិទ្ធិ [គ្មាន]
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ [គ្មាន]
- តម្លៃក្នុងមួយមូលបត្រកម្មសិទ្ធិ [គ្មាន]
- តម្លៃ IPO [គ្មាន]
- ចំនួនសរុបនៃភាគហ៊ុនដែលនៅសល់ [គ្មាន]
- មូលធនទីផ្សារ [គ្មាន]
- ការអនុញ្ញាតឲ្យមានទីផ្សារមូលបត្រ [គ្មាន]

២. ព័ត៌មានស្តីពីមូលបត្របំណុល (សម្រាប់ក្រុមហ៊ុនបោះផ្សាយបំណុល)

| ព័ត៌មាន | ការពិពណ៌នា |
|---|---|
| **ប្រភេទនៃមូលបត្របំណុល** | សញ្ញាបណ្ណសាជីវកម្ម |
| **និមិត្តសញ្ញា** | សញ្ញាបណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា ("សញ្ញាបណ្ណ") |
| **កាលបរិច្ឆេទបោះផ្សាយ** | ៩ មេសា ២០២០ |
| **ចំនួនសរុបនៃបំណុល** | ៨០ ពាន់លានរៀល (ឬ សមមូលជាប្រាក់ដុល្លាររហូតដល់ ២០ លានដុល្លារអាមេរិក ដោយយកចំនួនណាដែលតូចជាង) |
| **ចំនួនសរុបនៃមូលបត្របំណុលដែលនៅសល់** | មិនមាន |
| **ឥណប្រតិទាន** | ៥ ឆ្នាំ [២០២០-២០២៥] គិតចាប់ពីកាលបរិច្ឆេទបោះផ្សាយ |
| **កាលវិភាគបង់គូប៉ុង** | ត្រូវបង់ប្រចាំឆ្នាំនៅរៀងរាល់ថ្ងៃទី ០៩ ខែមេសា ឆ្នាំ.... |
| **អត្រាគូប៉ុង(%)** | ៥,៥% ក្នុងមួយឆ្នាំ |
| **ចំនួនសរុបនៃការបង់គូប៉ុង** | មិនមាន |
| **ចំណាត់ថ្នាក់លទ្ធភាពសង (ប្រសិនបើមាន)** | សញ្ញាបណ្ណត្រូវបានធានាដោយស្ថាប័ន CGIF។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ: មិនមានលក្ខខណ្ឌតម្រូវឱ្យធ្វើចំណាត់ថ្នាក់លទ្ធភាពសងលើសញ្ញាបណ្ណសាជីវកម្មដែលមានការធានានោះទេ ប៉ុន្តែបុគ្គលធានាតម្រូវឱ្យមានចំណាត់ថ្នាក់លទ្ធភាពសង។<br>ស្ថាប័ន CGIF មានលទ្ធភាពសងដូចតទៅ៖<br>- "AA/A-1+" កម្រិតសកល (រយៈពេលវែង និងរយៈពេលខ្លី) ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Standard & Poor's នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ |

| | |
|---|---|
| | - "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង RMA Rating នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៤<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង TRIS Rating ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Fitch Ratings នៃប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤<br>- "idAAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Pefindo Credit Rating Agency ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤ |

## ខ. តម្លៃមូលបត្រ និងបរិមាណនៃការលក់

| មូលបត្រ | | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តម្លៃលក់ | អតិបរមា | [គ្មាន] | | | | | | | | | | | |
| | មធ្យម | [គ្មាន] | | | | | | | | | | | |
| | អប្បរមា | [គ្មាន] | | | | | | | | | | | |
| បរិមាណលក់ | អតិបរមា | [គ្មាន] | | | | | | | | | | | |
| | មធ្យម | [គ្មាន] | | | | | | | | | | | |
| | អប្បរមា | [គ្មាន] | | | | | | | | | | | |

## គ. ការគ្រប់គ្រងម្ចាស់ភាគហ៊ុន (៣០% ឬលើសពី៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគហ៊ុន | ចំនួនភាគរយ |
|---|---|---|---|---|
| ១ | Clipper Holding Ltd | ហុងកុង | ៩៩៩ | ៩៩,៩% |
| សរុប | | | ៩៩៩ | ៩៩,៩% |

## ផ្នែកទី៥ - របាយការណ៍សវនកម្មផ្ទៃក្នុងស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក សម្រាប់ឆ្នាំ ២០២៤

### ១. សេចក្តីផ្តើម

មុខងារសវនកម្មផ្ទៃក្នុង គឺមានភាពឯករាជ្យពីផ្នែកគ្រប់គ្រងនិងប្រតិបត្តិការអាជីវកម្ម និងធ្វើរបាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការសវនកម្មនិងហានិភ័យនៃក្រុមហ៊ុន។ ក្រុមសវនកម្មផ្ទៃក្នុងផ្តល់ជំនួយតាមតំបន និងគណៈគ្រប់គ្រងក្រុមហ៊ុនដោយអនុវត្តតាមវិធីសាស្ត្រដែលផ្អែកលើហានិភ័យដើម្បីវាយតម្លៃជាឯករាជ្យនូវប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង និងនីតិវិធីគ្រប់គ្រងហានិភ័យ ភាពជឿជាក់លើព័ត៌មានដែលត្រូវបានប្រើសម្រាប់ការធ្វើរបាយការណ៍ និងការធ្វើសេចក្តីសម្រេចចិត្ត ការប្រើប្រាស់ធនធាន និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព និងការអនុលោមតាមស្តង់ដារសាជីវកម្ម ច្បាប់ គោលការណ៍អាជីវកម្មនិងអភិបាលកិច្ច។ មុខងារសវនកម្មផ្ទៃក្នុងត្រូវបានផ្តល់ជូនដោយ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌា និង ក្រុមហ៊ុន អ អិម អេ គ្រុប ខូអិលធីឌី។

### ២. ទំនួលខុសត្រូវនៃតួនាទីសវនកម្មផ្ទៃក្នុង

តួនាទីសវនកម្មផ្ទៃក្នុងមានទំនួលខុសត្រូវដូចតទៅ៖

ក. ធ្វើរបាយការណ៍សវនកម្មផ្ទៃក្នុងទាំងអស់ និងផ្តល់របាយការណ៍ទាំងនេះទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យ ដើម្បីពិនិត្យ វាយតម្លៃ និងបញ្ជូនទៅក្រុមប្រឹក្សាភិបាល

ខ. ផ្សព្វផ្សាយរាល់ការរកឃើញសំខាន់ៗដែលអាចជះឥទ្ធិពលដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន អ អិម អេ ស៊ី ទៅកាន់គណៈកម្មាធិការសវនកម្ម និងហានិភ័យ ឬនាយកឯករាជ្យ។

គ. រៀបចំការប្រជុំជាមួយគណៈកម្មាធិការសវនកម្ម និងហានិភ័យយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានថ្នាក់គ្រប់គ្រង

ឃ. អនុវត្តមុខងារផ្សេងៗទៀតដែលបានចាត់តាំងដោយ គណៈកម្មាធិការសវនកម្មនិងហានិភ័យ និង ក្រុមប្រឹក្សាភិបាល និង;

ង. មុខងារផ្សេងទៀតដែលកំណត់ដោយគណៈកម្មាធិការសវនកម្មនិងហានិភ័យ និងក្រុមប្រឹក្សាភិបាល។

### ៣. សកម្មភាពសវនកម្មផ្ទៃក្នុង ឆ្នាំ២០២៤

នៅក្នុងឆ្នាំ២០២៤ សវនកម្មផ្លូវការមួយក្រោមរូបភាពជាការតាមដាន (Follow Up) ត្រូវបានអនុវត្តដើម្បីវាយតម្លៃឡើងវិញនូវវឌ្ឍនភាពរបស់អាជីវកម្មក្នុងការអនុវត្តតាមអនុសាសន៍ពីសវនកម្មមុនៗទាំងអស់។ សវនកម្មនេះ បានរកឃើញថាមិនមានសកម្មភាពចំបងឬជាសារជាតុ (significant / material) ដែលខុសពីការរំពឹងទុកនោះទេ។

## ៩. សេចក្តីសន្និដ្ឋាន

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការវាយតម្លៃផ្អែកលើហានិភ័យប្រចាំឆ្នាំនៃអាជីវកម្មរបស់ក្រុមហ៊ុននិងគាំទ្រមុខងារ និងរាយការណ៍ការរកឃើញរបស់ខ្លួនទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យ និងនាយកប្រតិបត្តិការគ្រប់គ្រង។ ចំណុចដែលមានហានិភ័យត្រូវបានគូសបញ្ជាក់ឱ្យបានឃើញ ហើយអនុសាសន៍ក៏ត្រូវបានចេញ ដែលទាមទារឱ្យមានការកែតម្រូវផែនការសកម្មភាពដោយគណៈគ្រប់គ្រងដើម្បីអនុវត្តអនុសាសន៍ទាំងនោះសម្រាប់ឆ្នាំ២០២៤។

**បានអាន និង អនុម័ត**
**កាលបរិច្ឆេទ: ០២ មេសា ២០២៥**
**ហត្ថលេខា**



______________________

**ប្រធានសវនកម្ម និងហានិភ័យ**
**គណៈកម្មាធិការ**

**កាលបរិច្ឆេទ: ០២ មេសា ២០២៥**
**ហត្ថលេខា**



______________________

Veena Ananthawal
**ប្រធានសវនកម្មផ្ទៃក្នុង**

## ផ្នែកទី៦ - របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យដោយសវនករផ្ទៃក្នុង

សូមយោងលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤

## ផ្នែកទី៧ - ព័ត៌មានស្តីពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញឯកសារព័ត៌មានស្តីពីប្រតិបត្តិការ ភាគីដែលពាក់ព័ន្ធនៅកំឡុងពេលពីរឆ្នាំចុងក្រោយ បញ្ជាក់ឈ្មោះ ទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និង ប្រភេទនៃការប្រាក់ដែលកើតចេញពីទំនាក់ទំនងដូចខាងក្រោម:

ក. ឯកសារប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនដែលកាន់ភាគហ៊ុនយ៉ាងតិច៥% (ប្រាំភាគរយ) ឬច្រើននៃចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់
សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២៤ ចំនុច ២៧ "ភាគីពាក់ព័ន្ធ"

ខ. ឯកសារប្រតិបត្តិការជាមួយអភិបាល និងមន្ត្រីជាន់ខ្ពស់
សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២៤ ចំនុច ២៧"ភាគីពាក់ព័ន្ធ

គ. ប្រតិបត្តិការជាមួយអភិបាល និងម្ចាស់ភាគហ៊ុនពាក់ព័ន្ធដើម្បីទិញឬលក់ទ្រព្យសម្បត្តិ និងសេវាកម្ម
មិនមាន

ឃ. ឯកសារប្រតិបត្តិការជាមួយសមាជិកគ្រួសាររបស់អភិបាល មន្ត្រីជាន់ខ្ពស់ និងម្ចាស់ភាគហ៊ុនដែលកាន់ភាគហ៊ុនយ៉ាងតិច៥% (ប្រាំភាគរយ)ឬច្រើន
មិនមាន

ង. ឯកសារប្រតិបត្តិការជាមួយបុគ្គលដែលជាប់ទាក់ទងនឹងអភិបាលនៃក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនកាន់កាប់ដែលមានទំនាក់ទំនងនៅក្នុងប្រតិបត្តិការណាមួយ ឬបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ
មិនមាន

ច. ឯកសារប្រតិបត្តិការជាមួយអតីតអភិបាល ឬបុគ្គលដែលបានចូលរួមជាមួយអតីតអភិបាល
មិនមាន

ឆ. ឯកសារប្រតិបត្តិការជាមួយអភិបាលដែលកំពុងកាន់តំណែងនៅក្នុងអង្គការគ្មានប្រាក់ចំណូល ឬនៅក្នុងក្រុមហ៊ុនផ្សេងៗទៀតក្រៅពីក្រុមហ៊ុនបោះផ្សាយ
មិនមាន

ជ. ឯកសារប្រតិបត្តិការជាមួយនាយកដែលទទួលបានចំនូល ឬមិនបានចំណូលពីក្រុមហ៊ុនបោះផ្សាយ

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២៤ ចំនុច ២៧ "ភាគីពាក់ព័ន្ធ

សម្រាប់គោលបំណងនៃការបង្ហាញ កម្រិតតម្លៃនៃប្រតិបត្តិការសម្ភារៈត្រូវបានកំណត់ចំនួន USD ១០០.០០០

## ផ្នែកទី៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ១.៦៣១ ប៊ីលលានរៀល ក្នុងឆ្នាំ២០២៤ ដែលបានថយចុះចំនួន -១៦៩,៣ ប៊ីលលានរៀល ឬ -៩,៤% នៅក្នុងឆ្នាំ២០២៤ បើធៀបទៅនឹងឆ្នាំ២០២៣។

### ២. ផ្នែកនៃចំណូល

ផ្នែកបរិក្ខារកសិកម្ម (Agriculture Equipment) ផ្នែក Changan និង ផ្នែកបរិក្ខារធុនធ្ងន់(Heavy-Equipment) ការលក់បានកើនឡើងនៅឆ្នាំ២០២៤ បើធៀបទៅនឹងឆ្នាំមុន។ ផ្នែករថយន្ត Ford និង Land Rover មានការធ្លាក់ចុះចំណូលបន្ទិចបន្តួចក្នុងឆ្នាំ២០២៤ បើធៀបនឹងឆ្នាំមុន។

| គិតជាពាន់រៀល | ២០២៤ | ភាគរយ | ២០២៣ | ភាគរយ | ២០២២ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ១.៥២៩.១៣៣.៩៧៨ | ៩៣,៧% | ១.៧២៩.៥៦៦.២០៦ | ៩៦,១% | ២.១៤១.៧០២.៨២៨ | ៩៧,២% |
| **ចំណូលនៃសេវាកម្ម** | ១០១.៩៦១.៧១៦ | ៦,៣% | ៧០.៧៩៥.៨៨៨ | ៣,៩% | ៦១.៥៥០.៦២៥ | ២,៨% |
| **សរុប** | ១.៦៣១.០៩៥.៦៩៤ | ១០០,០% | ១.៨០០.៣៦២.០៩៤ | ១០០,០% | ២.២០៣.២៥៣.៤៥៣ | ១០០,០% |

### ៣. គម្លាតចំណេញដុល

| គិតជាពាន់រៀល | ២០២៤ | ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ១.៦៣១.០៩៥.៦៩៤ | ១.៨០០.៣៦២.០៩៤ | (១៦៩.២៦៦.៤០០) | -៩,៤% |
| **ចំណេញដុល** | ២៩៥.៤៤២.៣២៨ | ៣១២.៩៣០.៦៥៨ | (៦៧.៤៨៨.៣៣០) | -២១,៦% |
| **គម្លាតចំណេញដុល** | *១៥,០%* | *១៧,៤%* | | |

### ៤. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ២០២៤ | ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ១.៦៣១.០៩៥.៦៩៤ | ១.៨០០.៣៦២.០៩៤ | (១៦៩.២៦៦.៤០០) | -៩,៤% |
| **ចំណេញដុល** | ២៩៥.៤៤២.៣២៨ | ៣១២.៩៣០.៦៥៨ | (៦៧.៤៨៨.៣៣០) | -២១,៦% |
| **គម្លាតចំណេញដុល** | *១៥,០%* | *១៧,៤%* | | |
| **ចំណាយ** | ១៣៤.០៧៣.៩៥២ | ១៤៤.០៩៧.៩០៧ | (១០.០២៣.៩៥៥) | -៧,០% |
| **ចំណាយហិរញ្ញវត្ថុ** | ២៤.៩៩២.៩៦៨ | ២៩.៤១២.៤៥១ | (៤.៤១៩.៤៨៣) | -១៥,០% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ៨៨.០៨៣.៣៣៩ | ១៣៩.៤២០.៣០០ | (៥១.៣៣៦.៩៦១) | -៣៦,៨% |
| **គម្លាត** | *៥,៤%* | *៧,៧%* | | |

៥. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ២០២៤ | ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ៨៨.០៨៣.៣៣៩ | ១៣៩.៤២០.៣០០ | (៥១.៣៣៦.៩៦១) | -៣៦,៨% |
| **ចំណាយពន្ធ** | ២០.៤៦៤.២៤៩ | ២៥.៦៩៧.១៦៧ | (៥.២៣២.៩១៨) | -២០,៤% |
| **ប្រាក់ចំណេញក្រោយបង់ពន្ធ** | ៦៧.៦១៩.០៩០ | ១១៣.៧២៣.១៣៣ | (៤៦.១០៤.០៤៣) | -៤០,៥% |
| **គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ** | *៤,១%* | *៦,៣%* | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

អតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជា បង្ហាញពីចំណាប់អារម្មណ៍លើការទិញម៉ាកយីហោសំខាន់ៗរបស់ RMAC ដូចជា Ford, Changan, John Deere និង Land Rover។

RMAC បានធ្វើការតាមដានយ៉ាងជិតដល់នូវប្រភពបំពង់បង្ហូរប្រេង (sourcing pipeline) សម្រាប់ផ្នែកនីមួយៗដើម្បីធ្វើការសម្រេចចិត្តសមស្របទាក់ទងនិងការបញ្ជាទិញ។

២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

៣. ការវិភាគអំពីពន្ធដារ

ថ្មីៗនេះមិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងបទប្បញ្ញត្តិពន្ធនៅក្នុងប្រទេសកម្ពុជាដែលមានឥទ្ធិពលប៉ះពាល់ទៅលើដំណើរការហិរញ្ញវត្ថុរបស់យើងទេ។

៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ឆ្នាំ២០២៤ នឹងត្រូវប្រៀបធៀបជាមួយនឹងឆ្នាំ២០២៣ គឺនឹងត្រូវបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍សវនកម្មហិរញ្ញវត្ថុសង្ខេបដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុនមិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលនាំឱ្យមានការជះឥទ្ធិពលដល់អាជីវកម្មរបស់យើងឡើយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ៗ

មិនមានព្រឹត្តិការណ៍សំខាន់ផ្សេងទៀតទេ។

# ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ០២ មេសា ២០២៥

បានអាន និង អនុម័តដោយ:

..........................................

ហត្ថលេខា

ឈ្មោះ៖ លោក Kevin Whitcraft

តំណែង៖ ប្រធានក្រុមប្រឹក្សាភិបាល

បានអាន និង អនុម័តដោយ:

..........................................

ហត្ថលេខា

ឈ្មោះ៖ លោក Thomas Arthur Whitcraft

តំណែង៖ អភិបាលមិនប្រតិបត្តិ

បានអាន និង អនុម័តដោយ:

..........................................

ហត្ថលេខា

ឈ្មោះ៖ លោក **ងន សាំង**

តំណែង៖ អភិបាលប្រតិបត្តិ និងជា នាយកប្រតិបត្តិ

បានអាន និង អនុម័តដោយ:

..........................................

ហត្ថលេខា

ឈ្មោះ៖ លោក Wiedmann Apiwat Christian

តំណែង៖ អភិបាលមិនប្រតិបត្តិ

បានអាន និង អនុម័តដោយ:

..........................................

ហត្ថលេខា

ឈ្មោះ៖ លោក Vichit Ith

តំណែង៖ អភិបាលឯករាជ្យ

RMA CAMBODIA

ដើម្បីក្លាយជាដៃគូដែលជាទីទុកចិត្តបំផុត និងយូរ
អង្វែង សម្រាប់ការអភិវឌ្ឍន៍ និងវិបុលភាព នៅកម្ពុជា

